UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

## ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា និងការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

សេចក្តីថ្លែងការណ៍រួម ថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០០៩

កាលពីថ្ងៃទី ២២ និង២៣ ខែមករា ឆ្នាំ ២០០៩ ក្រសួងមហាផ្ទៃបានរៀបចំសិក្ខាសាលាមួយនៅប្រទេសកម្ពុជាស្តីអំពីការអនុវត្តន៍ពិធីសារបន្ថែមទៅលើអនុសញ្ញាប្រឆាំងនិងអំពើទារុណកម្ម ដោយមានការចូលរួមពីលោក ហាន្ស ដ្រាំមិនស្គី ភីទ័រសេន ជាអនុប្រធាននៃអនុគណៈកម្មាធិការបង្ការអំពើទារុណកម្ម ហើយដោយមានការគាំទ្រពីការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និងមជ្ឈមណ្ឌលស្រាវជ្រាវ និងស្តារនីតិសម្បទាសំរាប់ជនរងគ្រោះពីអំពើទារុណកម្ម ដែលមានទីស្នាក់ការនៅប្រទេសដាណឺម៉ាក ។

ព្រឹត្តិការណ៍ដ៏សំខាន់នេះ គឺជាឱកាសមួយសំរាប់រាជរដ្ឋាភិបាលធ្វើការបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួន ដែលបានធ្វើជាផ្លូវការនៅពេលរដ្ឋាភិបាលបានផ្តល់សច្ចាប័នទៅលើពិធីសារបន្ថែមនេះក្នុងឆ្នាំ ២០០៧ ដើម្បីលុបបំបាត់ការធ្វើទារុណកម្មនៅក្នុងប្រទេសកម្ពុជា ។

វាជាឱកាសមួយផងដែរដើម្បីសិក្សាលំអិត និងបញ្ជាក់ឱ្យបានច្បាស់នូវការប្តេជ្ញាចិត្ត ក្នុងការបង្កើតយន្តការបង្ការថ្នាក់ជាតិមួយក្រោមពិធីសារបន្ថែមនេះ ។

សិក្ខាសាលានេះនាំឱ្យមានការយល់ដឹងដូចគ្នាមួយថា ខណៈពេលដែលកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើតយន្តការបែបនេះមួយត្រូវបានទទួលស្វាគមន៍ នោះគប្បីត្រូវការពេលវេលាច្រើនថែមទៀត ដើម្បីបង្កើតយន្តការមួយនេះ ដែលនឹងស្របទាំងស្រុងទៅនឹងពិធីសារបន្ថែមទៅលើអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម និងគោលការណ៍ទីក្រុងប៉ារីស ។

យល់ដឹងផងដែរថា សេចក្តីពង្រាងអនុក្រឹត្យបច្ចុប្បន្ននឹងបង្កើតបានជា "ស្ថាប័នមួយបណ្តោះអាសន្នឆ្ពោះទៅរកការបង្កើតយន្តការបង្ការថ្នាក់ជាតិ " ហើយយន្តការនេះនឹងផ្អែកទៅលើច្បាប់មួយ ដែលនឹងត្រូវតាក់តែងឡើងដោយរដ្ឋាភិបាលក្នុងរយៈពេលមួយអាចថា ២ ឆ្នាំខាងមុខនេះ ។

លោក ភីទ័រ ស្វាគមនូវការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ដើម្បីសុំឱ្យអនុគណៈកម្មាធិការបង្ការអំពើទារុណកម្មចូលរួមពិភាក្សា នៅដំណាក់ការដ៏ឆាប់បំផុតនៃកិច្ចដំណើរការនេះ ដើម្បីឱ្យអនុគណៈកម្មាធិការនេះ អាចផ្តល់យោបល់និងជួយដល់រាជរដ្ឋាភិបាល ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្កើតឱ្យបាននូវយន្តការបង្ការថ្នាក់ជាតិនេះនៅពេលអនាគត ។